ប្រសាសន៍ទាំងស្រុងរបស់

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ថ្លែងនៅក្នុងកិច្ចប្រជុំកំពូលលើកទី៥ ដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី៤០

នៃទំនាក់ទំនងកិច្ចសន្ទនាអាស៊ាន-សហរដ្ឋអាមេរិក

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧

នៅទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន

---

**ឯកឧត្តមប្រធាន!**

**ឯកឧត្តមប្រធានាធិបតី ដូណាល់ ត្រាំ!**

ដំបូង ខ្ញុំសូមសម្តែងការឯកភាពជាមួយនឹង ឯកឧត្តមនាយករដ្ឋមន្ត្រី **ណាហ្ស៊ីប រ៉ាហ្សាក់** នៃប្រទេសម៉ាឡេស៊ី ដែលជាប្រទេសសម្របសម្រួលធ្វើការបូកសរុប។ អម្បាញ់មិញ ក៏ជាការឆ្លើយតបដ៏អស្ចារ្យមួយរបស់ឯកឧត្តមប្រធានាធិបតី ដូណាល់ ត្រាំ។

ឯកឧត្តមប្រធានាធិបតី!

ឯកឧត្តមគឺជាមនុស្សដ៏អស្ចារ្យមួយសម្រាប់ខ្ញុំ ។ ខ្ញុំគួរតែបញ្ជាក់នៅទីនេះថា៖ ប្រហែលជាឪពុករបស់ខ្ញុំបានស្លាប់ទៅហួស ដែលគាត់មិនបានស្តាប់ឮសម្តីរបស់ប្រធានាធិបតីសហរដ្ឋអាមេរិកមួយ ដែលបាននិយាយនៅឯអង្គការសហប្រជាជាតិ និយាយនៅ APEC ហើយនិយាយនៅថ្ងៃនេះ។ នៅត្រង់ថា ឯកឧត្តម បាននិយាយ៖ «*យើងគោរពឯករាជ្យ និងអធិបតេយ្យភាពនៃប្រទេសរបស់អ្នក យើងចង់ឱ្យអ្នកខ្លាំង រីកចម្រើន និងមានឯករាជ្យដោយខ្លួនឯង ចាក់រឹសជ្រៅក្នុងតម្លៃប្រវត្តិសាស្ត្ររបស់អ្នក និងប្រឹងប្រែងដើម្បីអនាគតល្អប្រសើរនៃប្រជាជនអ្នក។* នេះជាអ្វីដែលយើងប្រឹងប្រែងទាំងអស់គ្នា ហើយរីកចម្រើនជាមួយគ្នានឹងភាពជាដៃគូពិត និងជាដៃគូយូរអង្វែង។ ខ្ញុំគិតថា ឯកឧត្តមគឺជាមនុស្សដ៏អស្ចារ្យ ហើយជាមនុស្សដែលខ្ញុំគោរពបំផុត។ រឿងនេះ ខ្ញុំក៏គួបញ្ជាក់ជូនបន្តិចក្រៅប្រធានបទ តែអាចនៅក្នុងប្រធានបទរវាងទំនាក់ទំនងសហរដ្ឋអាមេរិកជាមួយប្រទេសដទៃទៀត។

ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមមនុស្ស១០០នាក់ ដែលពេលនោះនៅកម្ពុជា គេចាត់ទុកថាឯកឧត្តមមានលទ្ធភាពឈ្នះឆ្នោតត្រឹមតែ១ភាគរយប៉ុណ្ណោះ។ ៩៩ភាគរយ ឯកឧត្តមគឺជាអ្នកចាញ់។

ក៏ប៉ុន្តែ ខ្លួនខ្ញុំ ស្ថិតនៅក្នុងចំណោម១ភាគរយ។ មុនពេលបោះឆ្នោតខ្ញុំបានប្រកាសពីរលើកថា ឯកឧត្តម ជាអ្នកឈ្នះឆ្នោត។ ប៉ុន្តែ ខ្ញុំបែរជាទទួលនូវការវាយប្រហារ ពីប្រធានបក្សប្រឆាំងថា៖ «សត្វដែលមានរោមដូចគ្នា វានៅក្នុងសំបុកជាមួយគ្នាបាន។ ដូណាល់ ត្រាំ គឺជាអ្នកផ្តាច់ការដោយសារលុយ ឯ ហ៊ុន សែន ជាអ្នកផ្តាច់ការ ដោយសារលុយនិងអាវុធ»។ ឯសាស្ត្រាចារ្យខ្មែរម្នាក់ ដែលជាសាស្ត្រាចារ្យនៅសហរដ្ឋអាមេរិក គេបាននិយាយថា៖ បើ ដូណាល់ ត្រាំ ឈ្នះឆ្នោត គឺជាយុគសម័យនៃការរះឡើងនៃពួកអវិជ្ជា។ អញ្ចឹងទេ ខ្ញុំបានក្លាយជាមុខសញ្ញានៃការវាយប្រហារ។ ក៏ប៉ុន្តែ ខ្ញុំមានមោទនភាព ដោយសារអ្វីដែលខ្ញុំបានប្រកាសនៅមុនការបោះឆ្នោត គឺ ឯកឧត្តម ក្លាយទៅជាអ្នកឈ្នះពិត។ ប៉ុន្តែ សូមកុំភ្លេចថា ចៅរបស់ខ្ញុំត្រូវបានគេបង្ខាត់បង្រៀនឱ្យស្អប់ឯកឧត្តម។ នេះបង្ហាញឱ្យឃើញថា ស្ថានទូតអាមេរិក នៅទីក្រុងភ្នំពេញ មិនត្រឹមតែមិនមានអព្យាក្រឹត្យចំពោះបញ្ហាប្រទេសកម្ពុជាទេ មិនមានអព្យាក្រិត្យទាំងបេក្ខជនប្រធានាធិបតីនៅសហរដ្ឋអាមេរិកខ្លួនឯងតែម្តង។ ចំណុចនេះ ខ្ញុំចង់ជម្រាបជូន ឯកឧត្តមថា សហរដ្ឋអាមេរិក បើសិនជាអនុវត្តតាមគោលនយោបាយថ្មីរបស់ឯកឧត្តម ក្នុងការគោរពឯករាជ្យ អធិបតេយ្យភាពនៃប្រទេសដទៃ សហរដ្ឋអាមេរិកនឹងមានមិត្តភក្តិច្រើនណាស់ ហើយគេគោរព និងគេស្រឡាញ់។

ក៏ប៉ុន្តែ រយៈពេលកន្លងទៅនេះ ខ្ញុំសូមជម្រាបថា ប្រទេសនៅទីនេះ ខ្ញុំគិតថា គ្រាន់តែមានអ្នកហ៊ាននិយាយ និងមិនហ៊ាននិយាយតែប៉ុណ្ណោះ គឺនៅត្រង់ថា រដ្ឋកាលមុនៗ គេបានប្រើប្រាស់នូវលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សដើម្បីជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់អ្នកដទៃ។ យើងខ្ញុំជាជនរងគ្រោះម្តងហើយម្តងទៀត ឥឡូវកំពុងត្រូវបន្តក្លាយជាជនរងគ្រោះ ដោយសារតែសកម្មភាពរបស់អ្នកខាងក្រោមដែលដើរខុសពីបន្ទាត់នយោបាយរបស់ឯកឧត្តម។ នយោបាយរបស់ឯកឧត្តម កំពុងតែធ្វើការកែប្រែ ប៉ុន្តែស្ថានទូតនៅទីក្រុងភ្នំពេញ មិនទាន់បានធ្វើការកែប្រែទេ។ យើងខ្ញុំត្រូវការកសាងច្បាប់ គេមករារាំងការកសាងច្បាប់។ យើងខ្ញុំអនុវត្តច្បាប់របស់ប្រទេស ត្រូវបានគេរារាំង។ ចំណុចនេះ ខ្ញុំគិតថាប្រហែលជាឯកឧត្តម ត្រូវមានការកិច្ចដើម្បីដាស់តឿនជាមួយនឹង មន្ត្រីទាំងឡាយ ព្រោះរឿងនេះជាគោលការណ៍ធំណាស់ ទាក់ទងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងគេ។

ហើយខ្ញុំក៏សូមបញ្ជាក់ជូន ឯកឧត្តម ផងដែរថា បញ្ហាបំណុលកម្ពុជា មានជាមួយសហរដ្ឋអាមេរិក គឺជាបញ្ហាមួយដែលខ្ញុំធ្លាប់និយាយជាមួយប្រធានាធិបតី អូបាម៉ា។ រឿងនេះ វាដូច្នេះ ៖ គឺនៅត្រង់ថា កម្ពុជាត្រូវបានទម្លាក់ដោយរដ្ឋប្រហារមួយដែលគាំទ្រដោយសហរដ្ឋអាមេរិក ហើយបានក្លាយទៅជាប្រទេសដែលជំពាក់បំណុលសហរដ្ឋអាមេរិក ហើយបំណុលនោះទៀតសោត គឺយើងខ្ញុំ

ជាអ្នកទទួលមរតក ដូច្នេះយើងខ្ញុំត្រូវមានភារកិច្ចសង។ យើងខ្ញុំបានស្នើសុំថា យើងខ្ញុំសង ប៉ុន្តែសុំស្នើឱ្យអាមេរិកបង្វែរប៉េណុលនោះមកជួយដល់កម្ពុជាវិញ។ ចំណុចនេះ គឺជាចំណុចដែលយើងខ្ញុំស្នើសុំឱ្យឯកឧត្តមធ្វើការពិចារណា ព្រោះថា វាដូចជាការយកញញួរមកវ៉ៃ យើងខ្ញុំហើយ ហើយឱ្យយើងខ្ញុំសងថ្លៃញញួរនោះទៅទៀត។ ព្រោះជំនួយនេះ មិនដឹងថាគេយកមកធ្វើអី ហើយគេទិញអាវុធមកធ្វើសង្គ្រាមនៅកម្ពុជាក្នុងពេលដែលយើងខ្ញុំ នៅក្មេងៗនៅឡើយ។ ប៉ុន្តែ មរតកដ្ឋ យ៉ាងណាក៏ដោយយើងខ្ញុំត្រូវតែគោរព។

ខ្ញុំគិតថា ឯកឧត្តមប្រធានាធិបតី មិនប្រកាន់នឹងខ្ញុំទេ ខ្ញុំមិនដឹងថា តើឯកឧត្តម ដូចខ្ញុំ ឬខ្ញុំដូច ឯកឧត្តមទេ? ព្រោះថាជាមនុស្សដែលចូលចិត្តនិយាយត្រង់ដូចគ្នា ប៉ុន្តែដោយសារឯកឧត្តមជាមនុស្សចាស់ ខ្ញុំដូចឯកឧត្តមទៅវិញ។ កាលពីឆ្នាំទៅ ខ្ញុំក៏បាននិយាយជាមួយ ឯកឧត្តម ឌូទឺតេ ដូចគ្នាដែរ តើឯកឧត្តម ឌូទឺតេ ដូចខ្ញុំ? ឬខ្ញុំដូចឯកឧត្តម ឌូទឺតេ? ព្រោះ ពិតមែនតែខ្ញុំ ធ្វើជានាយករដ្ឋមន្ត្រីយូរឆ្នាំ មុនឯកឧត្តម ឌូទឺតេ មុនឯកឧត្តមប្រធានាធិបតី ក៏ប៉ុន្តែ ដោយសារខ្ញុំមានអាយុតិចជាង អញ្ចឹងទេខ្ញុំសូមអធ្យាស្រ័យនៅអ្វីដែលខ្ញុំបានលើកនៅទីនេះ ដែលវាខុសនឹងប្រធានបទ។

ប៉ុន្តែចំណុច ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងនេះ ជាចំណុចសំខាន់ណាស់ នៅក្នុងគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក ហើយអាមេរិកអាចនឹងមានដៃគូ និងមិត្តភក្តិ ដ៏ជាទីស្រលាញ់ របស់ខ្លួនកាន់តែច្រើន ហើយពេលនោះ សហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម វិនិយោគនានា នឹងចាប់ផ្តើមពីជំនឿទុកចិត្តនេះឯង។

*សូមអរគុណ!*